ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ពិសេស ធទឧ

# សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពអាកាសធាតុក្នុងរដូវវស្សា ឆ្នាំ 2015

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា ខ្យល់មូសុងនិរតី ( មូសុងវស្សា ) នឹងចាប់ផ្តើមមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី 04 ឬថ្ងៃទី 05 ខែឧសភា ឆ្នាំ 2015 ខាងមុខនេះ ។

យោងតាមការព្យាករ ក្នុងរដូវវស្សា ឆ្នាំ 2015 ស្ថានភាពអាកាសធាតុមានដូចខាងក្រោម :

១- ភ្លៀងរដូវវស្សា នឹងចាប់ផ្តើមធ្លាក់រាយប៉ាយក្នុងក្របខ័ណ្ឌទូទាំងប្រទេសជាបន្តបន្ទាប់ ចាប់ពីដើមខែឧសភានេះតទៅ ។ បរិមាណទឹកភ្លៀងដែលនឹងត្រូវធ្លាក់ចុះ មាន :

- **ចាប់ពីខែឧសភា ដល់ខែមិថុនា** : បរិមាណទឹកភ្លៀង មានក្នុងកម្រិតពីតិច ទៅបង្គួរ ។
- **ចាប់ពីខែកក្កដា ដល់ខែតុលា** : បរិមាណទឹកភ្លៀង មានក្នុងកម្រិតច្រើន ។

២- បាតុភូតផ្គរ រន្ទះ លាយឡំនឹងខ្យល់កន្ត្រាក់ នៅបន្តកើតមានច្រើន រហូតដល់ពាក់កណ្តាលខែមិថុនា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។ ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានលើស្ថានភាពអាកាសធាតុនារដូវវស្សានេះជាប់ជាប្រចាំ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែម ក្នុងករណីចាំបាច់ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែឧសភា ឆ្នាំ2015*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh